**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍បាត់ដំបង**
**សំណុំរឿងសភាព្រហ្មទណ្ឌលេខ៖ ២៧៣**
ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២
**សាលដីកាលេខ: ៤៤៤ (ឧ)**
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

# សាលដីកា
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍បាត់ដំបង

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០១៤ បានធ្វើការបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃព្រហស្បតិ៍ ១៣កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦ ត្រូវនឹងថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ ដែលមានសមាសភាពដូចខាងក្រោម៖

<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>

17.10.22

សល់ 12 ថ្ងៃ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

លោក [redacted] ជាព្រះរាជអាជ្ញា

<u>ក្រឡាបញ្ជីសវនាការ</u>

លោកស្រី [redacted] ជាក្រឡាបញ្ជីសវនាការ

ដើម្បីជំនុំជម្រះលើសំណុំរឿងសភាព្រហ្មទណ្ឌលេខ៖ ២៧៣ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង មានដូចខាងក្រោម៖

**<u>ជនជាប់ចោទ៖</u>**

ឈ្មោះ [redacted] សូម ភេទស្រី អាយុ ៦៦ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអូររូង ឃុំតាជេស ស្រុកកំពង់តាឡាច ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃភូមិអូររូង ឃុំតាជេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ប្តីឈ្មោះ [redacted](ស) មានកូនចំនួន ០៥នាក់ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted](ស) ទោសពីមុន "គ្មាន"។ (ក្រៅឃុំ)

ជាប់ចោទពីបទ: ប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិខ្លាក្រពើ ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីឆ្នាំ២០១៣ រហូតដល់ខែសីហា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៤៨ និងមាត្រា២៥៣ នៃច្បាប់ភូមិបាល។

ដោយមានលោក[redacted]ចន្ទុល ជាមេធាវីការពារសិទ្ធិ។



Scanned with CamScanner

ឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៤៨ និងមាត្រា២៥៣ នៃច្បាប់ភូមិបាល។

**ដើមបណ្តឹងរដ្ឋប្បវេណី៖**

ឈ្មោះ[redacted]ជឿន ភេទស្រី អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន នៅភូមិក្រសះថ្មី ឃុំឈូកសរ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

**អំពីអង្គហេតុ**

កាលពីឆ្នាំ២០១៣ រហូតលដល់ខែសីហា ឆ្នាំ២០១៩ មានអំពើ ប៉ះពាល់កម្មសិទ្ធិឯកជន បានកើតឡើងនៅចំណុចភូមិខ្លាក្រពើ ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] សូម ភេទស្រី អាយុ ៦៦ឆ្នាំ។ ដោយដំបូងឈ្មោះ[redacted]សូម បានទៅសុំដីរបស់ឈ្មោះ[redacted] ជឿន ភេទស្រី អាយុ៤៨ឆ្នាំ រស់នៅជាបណ្តោះអាសន្ន ដែលដីនេះមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ត្រឹមត្រូវ ក្រោយមកនៅក្នុងឆ្នាំ២០១៣ ស្រាប់តែឈ្មោះ[redacted]សូម បានលួចធ្វើវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ ដាក់ឈ្មោះខ្លួនឯងវិញ ក្នុងបំណងយកដីធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនវិញ។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ៦៥១-ក- ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted]សូម ភេទស្រី កើតឆ្នាំ១៩៥៤ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១ឆ្នាំ (មួយឆ្នាំគត់) គិតពីថ្ងៃអនុវត្តទោសតាមអំណាចសាលក្រមនេះ:

ពីបទ: ប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិខ្លាក្រពើ ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីឆ្នាំ២០១៣ រហូតដល់ខែសីហាឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទា-ទោសតាមមាត្រា២៤៨ និង២៥៣ នៃច្បាប់ភូមិបាល។

២-បង្គាប់ឱ្យជនជាប់ចោទ [redacted] សូម បង់សំណងការខូចខាតជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ជឿន ចាប់ពីថ្ងៃនេះតទៅ។

៣-សាលក្រមនេះធ្វើការជំនុំជម្រះ និងប្រកាសសាធារណៈកំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ: ២៣(ក) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានសេចក្តីសម្រេចដូតទៅ៖

១-បដិសេធចោលលើបណ្តឹងទាស់របស់ពិរុទ្ធជនឈ្មោះ[redacted]សូម ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០។

២-តម្កល់សាលក្រមលេខ:៦៥១(ក) ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ទុកជាបានការពេញទាំងមូលដដែល។

៣-សាលក្រមនេះបានជំនុំជម្រះ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ និងប្រកាសជាសាធារណៈថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងពិរុទ្ធជន ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-**បានឃើញ** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ[redacted] សូម ដែលបានសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ២៣(ក) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២



Scanned with CamScanner

របស់សាលាដំបូងខេត្តពោធិ៍សាត់ លើគ្រប់ចំណុចនៃសេចក្ដីសម្រេចរបស់សាលក្រម។

-**បានឃើញ** របាយការណ៍រឿងចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍បាត់ដំបង។

-**បានឃើញ** សេចក្ដីសន្និដ្ឋានចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ របស់តំណាងមហាអយ្យការអម សាលាឧទ្ធរណ៍បាត់ដំបង។

**<u>នាពេលសវនាការ</u>**

-ក្រឡាបញ្ជីត្រួតពិនិត្យវត្តមាន។

-ជនជាប់ចោទឈ្មោះ [redacted] សូម (អវត្តមាន)។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជឿន (មានវត្តមាន)។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចន្ទុល (មានវត្តមាន)។

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង និងប្រាប់សិទ្ធិដល់ជនជាប់ចោទ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជឿន បានឆ្លើយថា៖ ដីនេះបច្ចុប្បន្នខ្លួនបានទទួលប្លង់រឹងទាំងពីរ ហើយខ្លួនជាអ្នកកាន់កាប់ ប៉ុន្តែកំពុងជាប់រក្សាការពារ ទុកឱ្យនៅទំនេរ។ ដំបូងឡើយខ្លួនបានទិញដីឆ្នាំ ២០០៦ ធ្វើប្លង់រឹងក្នុងឆ្នាំ២០០៧ ហើយឈ្មោះ [redacted] សូម បានសុំខ្លួនស្នាក់នៅក្នុងឆ្នាំ២០០៨ ខ្លួននឹកឃើញថាបងប្អូនក៏ឱ្យស្នាក់នៅហើយគាត់ក៏បានលួចធ្វើប្លង់លើដីរបស់ខ្លួន។ ខ្លួនឃើញថាដីខ្លួនមានស្មៅច្រើនពេក ខ្លួនក៏ទៅធ្វើស្មៅស្រាប់តែឈ្មោះ [redacted] សូម ថាជាដីរបស់គាត់ គាត់មានសិទ្ធិ និងប្លង់។ ខ្លួនក៏បានហៅគាត់មកសម្រុះសម្រួលនៅភូមិឃុំ ហើយបានឱ្យលុយទៅឈ្មោះ [redacted] សូម ចំនួន ៧៥០០$ ដើម្បីទៅរំលស់ប្លង់នៅធនាគារ។ ហើយសព្វថ្ងៃឈ្មោះ [redacted] សូម មិនបានរស់នៅលើដីរបស់ខ្លួនទៀតទេ។

-ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សូម បានឆ្លើយថា ៖ មូលហេតុដែលខ្លួនប្ដឹងទាស់នឹងសាលក្រមលេខ ៦៥១ (ក) ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ព្រោះដីនោះជាដីរបស់ខ្លួន ហើយគេហៅខ្លួនយកមកឃុំខ្លួនតែម្ដង បានមួយរយៈទើបឱ្យខ្លួនចេញ។ ហើយសាលក្រមនេះ បានសម្រេចផ្ដន្ទាទោសខ្លួនមួយឆ្នាំហើយ និងឱ្យបង់ជម្ងឺចិត្តចំនួន ១០.០០០.០០០ (ដប់លាន) រៀល ទៀត។ ដីនោះសព្វថ្ងៃទុកចោលបន្ទាប់ពីម្ចាស់គេទៅដេញខ្លួនចេញ។ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនមានលិខិតស្នាក់នៅ និងមានប័ណ្ណវាស់វែងដោយនិស្សិត។ ដីនោះឈ្មោះ [redacted] ស្មាន ជាអ្នកទិញហើយមិនទាន់ធ្វើប័ណ្ណទេ ដល់ពេលនិស្សិតចុះវាស់ វែងខ្លួនក៏ធ្វើប្លង់ដាក់ឈ្មោះខ្លួន ចំពោះការយកលុយទៅលោះប្លង់ពីធនាគារ គឺដើមបណ្ដឹងយកលុយទៅរំលស់ខ្លួនឯង។ ខ្លួនធ្វើប្លង់នោះ គឺអាងតែប្អូនទិញឱ្យខ្លួនមិនបានបំពានទេ។ ចំពោះការលោះប្លង់ គឺគេបានឱ្យលុយខ្លួនចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ហើយពេលទៅលោះប្លង់ ខ្លួនមិនបានដឹងថាឈ្មោះ [redacted] ជឿន មានប្លង់នោះទេ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីរបស់ឈ្មោះ [redacted] ស៊ីផាន់ (ស្មៀនឃុំអន្លង់ត្នោត) បានឆ្លើយថា ៖ ខ្លួនធ្វើការនៅសាលាឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ចំនួន ០៧ឆ្នាំមកហើយ ដីនេះមានទំនាស់ជាមួយឈ្មោះ [redacted] ជឿន និងឈ្មោះ [redacted] សូម ដោយសារខ្លួនបានដឹងថាដីខាងលើនេះ គឺដើមឡើយជារបស់ឈ្មោះ [redacted] ជឿន។ ក្រោយមកមានឈ្មោះ [redacted] សូម បានយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមក



Scanned with CamScanner

បញ្ជាក់នៅភូមិ-ឃុំ ដើម្បីទៅយកប្រាក់ខ្ចីធនាគារ រួចអាជ្ញាធរបានចេញឱ្យ។ បន្ទាប់មកឈ្មោះ[redacted]ជឿន បាន ឈូសឆាយដី ស្រាប់តែឈ្មោះ[redacted]សូម បានអះអាងថាជាដីគាត់ បន្ទាប់មកអ្នកទាំងពីរបានមកសាលាឃុំ ហើយអ្នកទាំងពីរ បានបង្ហាញប្លង់លើដីដែលទំនាស់នោះរៀងខ្លួន ក្រោយមកទើបអាជ្ញាធរដឹងថាដីខាងលើ នេះមានប្លង់ចំនួនពីរទៅវិញ ដោយប្លង់របស់ឈ្មោះ [redacted]ជឿន ជាម្ចាស់កម្មសិទ្ធិ។ ខ្លួនមិនដែលឃើញឈ្មោះ [redacted] សូម និងឈ្មោះ[redacted]ជឿន លក់ទិញដីជាមួយគ្នានោះទេ។ ហើយខាងអាជ្ញាធរ បានដោះស្រាយដោយ ឈ្មោះ[redacted] សូម បានប្រគល់ដីឱ្យទៅឈ្មោះ [redacted] ជឿន វិញដោយឈ្មោះ [redacted] សូម ទាមទាប្រាក់ចំនួន ៧៥០០ ដុល្លារ ដើម្បីយកលោះប្លង់នៅធនាគារ ហើយឈ្មោះ [redacted] ជឿន បានប្រគល់ប្រាក់ឱ្យហើយបាន យកប្លង់មកវិញ និងបានប្រគល់ជូនទៅឈ្មោះ[redacted]ជឿន។ ហើយឈ្មោះ[redacted]សូម បានព្រមផ្តិតមេដៃប្រគល់ សិទ្ធិកាន់កាប់ឱ្យឈ្មោះ[redacted] ជឿន វិញ តែដោយសារតែជាទ្រព្យរួម ទើបមិនអាចប្រគល់បាន ដោយរង់ចាំការ សម្រេចរបស់តុលាការសិន។

-តំណាងមហាអយ្យការបានធ្វើការសន្និដ្ឋានថា៖ ចំពោះរឿងនេះជនជាប់ចោទដែលជាអ្នកប្តឹងឧទ្ធរណ៍ គឺមិនបានឆ្លើយនៅចំពោះមុខអង្គសវនាការ ដោយលើកភស្តុតាង ឬហេតុផល ដើម្បីបន្ថែមទៅលើសំណុំរឿង ទេ ដូច្នេះតំណាងមហាអយ្យការមិនមានអ្វីត្រូវសន្និដ្ឋានបន្ថែម គប្បី ក្រុមប្រឹក្សា សម្រេច តម្កល់សាលក្រម សាលាដំបូង ទុកជាបានការ។

-លោក[redacted] ចន្ទុល ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លង កាត់តាមការត្រួតពិនិត្យឯកសារ ក៏ដូចជាចម្លើយរបស់កូនក្តីរបស់ខ្លួន ឃើញថា កូនក្តីរបស់ខ្លួនពិតជាម្ចាស់ កម្មសិទ្ធិពិតប្រាកដមែន ដែលមានឯកសារប្លង់រឹងតាំងពីឆ្នាំ២០០៧ មកម្លេស ដែលមានគល់បញ្ជីត្រឹមត្រូវ ហើយជនជាប់ចោទត្រូវជាបងប្អូន និងសុំកូនក្តីរបស់ខ្លួនស្នាក់នៅតែប៉ុណ្ណោះ មូលហេតុដែលមានអង្គហេតុ មកជំនុំជម្រះនៅថ្ងៃនេះគឺដោយសារតែឈ្មោះ [redacted] សូម គាត់បានលួចធ្វើប័ណ្ណកម្មសិទ្ធិថ្មី នៅឆ្នាំ២០១៣ ដោយធ្វើការយកប្លង់ទៅដាក់ធនាគារថែមទៀត។ ម្យ៉ាងទៀតកូនក្តីរបស់ខ្លួន និង[redacted]សូម បានធ្វើការសម្រប សម្រួលគ្នានៅឆ្នាំ២០១៩ ដោយជនជាប់ចោទបានសុខចិត្តប្រគល់ដីឱ្យកូនក្តីរបស់ខ្លួន ហើយកូនក្តីរបស់ខ្លួន បានឱ្យប្រាក់ចំនួន ៧៥០០$ ដើម្បីយកទៅរំលស់ប្លង់នៅធនាគារទៀត ដែលមានឯកសារជាភស្តុតាងត្រឹម ត្រូវ។ ម្យ៉ាងទៀតការអះអាងរបស់គាត់នៅក្នុងសវនាការនៅឆ្នាំ២០២០ ពាក់ព័ន្ធសាលក្រមលេខ ៦៥១"ក" ចុះ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ គាត់ថាយកតាំងពីឆ្នាំ២០១៤ ប៉ុន្តែដីជាក់ស្តែងទិញក្នុងឆ្នាំ២០១៦ ដូច្នេះការ អះអាងរបស់ជនជាប់ចោទ ធ្វើយ៉ាងមិចក៏ដោយ ដើម្បីយកដីចេញពីកូនក្តីរបស់ខ្លួន ដែលជាម្ចាស់កម្មសិទ្ធិ ស្របច្បាប់។ ស្នើសុំឯកភាពទៅនឹងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ជឿន។
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]សូម។
- ក្រោយពីបានស្តាប់អំណានចម្លើយសាក្សីរបស់ឈ្មោះ [redacted] ស៊ីជាន់ (ស្មៀនឃុំអន្លង់ត្នោត)។
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។
- ក្រោយពីបានស្តាប់ការធ្វើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
- ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី។



Scanned with CamScanner

➢ ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>**សំអាងហេតុ**</u>

១. **យល់ឃើញថា** បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ[redacted] សូម ដែលបានសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ:២៣(ត) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ លើគ្រប់ចំណុចនៃសេចក្តីសម្រេចរបស់សាលក្រម ដែលបណ្តឹងនេះធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ និងរយៈពេលដែលច្បាប់បានកំណត់ នាំឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបងមានសមត្ថកិច្ច និងសម្រេចសេចក្តីស្របតាមបញ្ញត្តិមាត្រា៤៣ នៃ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ តាមមាត្រា៣៧៣ ,៣៧៥ ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៤៧,៣៦៨,៣៧២ និង៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. **យល់ឃើញថា** ជនជាប់ចោទឈ្មោះ[redacted]សូម បានទទួលដំណឹងអំពីសវនាការនៅថ្ងៃទី០១ ខែកញ្ញា និងថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ រួចហើយតែជនជាប់ចោទពុំបានចូលខ្លួនមកបំភ្លឺ ចំពោះបណ្តឹងឧទ្ធរណ៍របស់ខ្លួនតាមការកោះហៅរបស់សាលាឧទ្ធរណ៍បាត់ដំបង ដើម្បីបង្ហាញភស្តុតាងថ្មី ដោះបន្ទុកឱ្យរួចផុតពីការចោទប្រកាន់ឡើយ គប្បីក្រុមប្រឹក្សា នៃសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបង ពិចារណាលើភស្តុតាងនានា ដែលមានក្នុងសំណុំរឿង មុនពេលមានបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ។

៣. **យល់ឃើញថា** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] ជឿន បានឆ្លើយថា៖ ដីនេះបច្ចុប្បន្នខ្លួនបានទទួលប្លង់រឹងទាំងពីរ ហើយខ្លួនជាអ្នកកាន់កាប់ ប៉ុន្តែកំពុងជាប់រក្សាការពារ ទុកឱ្យនៅទំនេរ។ ដំបូងឡើយខ្លួនបានទិញដីឆ្នាំ២០០៦ ធ្វើប្លង់រឹងក្នុងឆ្នាំ២០០៧ ហើយឈ្មោះ[redacted]សូម បានសុំខ្លួនស្នាក់នៅក្នុងឆ្នាំ២០០៨ ខ្លួននឹកឃើញថាបងប្អូនក៏ឱ្យស្នាក់នៅហើយគាត់ក៏បានលួចធ្វើប្លង់លើដីរបស់ខ្លួន។ ខ្លួនឃើញថាដីខ្លួនមានស្មៅច្រើនពេក ខ្លួនក៏ទៅធ្វើស្មៅ ស្រាប់តែឈ្មោ[redacted]សូម ថាជាដីរបស់គាត់ គាត់មានសិទ្ធិ និងប្លង់។ ខ្លួនក៏បានហៅគាត់មកសម្រុះ សម្រួលនៅភូមិឃុំ ហើយបានឱ្យលុយទៅឈ្មោះ[redacted]សូម ចំនួន ៧៥០០$ ដើម្បីទៅរំលស់ប្លង់នៅធនាគារ។ ហើយសព្វថ្ងៃឈ្មោះ[redacted]សូម មិនបានរស់នៅលើដីរបស់ខ្លួនទៀតទេ។

ដែលតាមចម្លើយនេះ មានមូលដ្ឋានឱ្យក្រុមប្រឹក្សានៃសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបង លើកយកមកពិចារណាដោយផ្អែកលើភស្តុតាង វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០០៤៤៨៨ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៧ ឃើញថាឈ្មោះ[redacted]សូម ពិតជាបានលួចធ្វើវិញ្ញាបនបត្រសម្គាល់អចលនវត្ថុថ្មីប្រាកដមែន។

៤. **យល់ឃើញថា** ផ្អែកតាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]សូម បានឆ្លើយថា៖ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ខ្លួនមានលិខិតស្នាក់នៅ និងមានប័ណ្ណពិសរបែងដោយនិស្សិត។ ដីនោះឈ្មោះ[redacted]ស្នាន ជាអ្នកទិញហើយមិនទាន់ធ្វើប័ណ្ណទេ ដល់ពេលនិស្សិតចុះវាស់វែងខ្លួនក៏ធ្វើប្លង់ដាក់ឈ្មោះខ្លួន ចំពោះការយកលុយទៅលោះប្លង់ពីធនាគារ គឺដើមបណ្តឹងយកលុយទៅរំលស់ខ្លួនឯង។ ខ្លួនធ្វើប្លង់នោះ គឺអាងតែប្អូនទិញឱ្យខ្លួនមិនបានបំពានទេ។ ចំពោះការលោះប្លង់ គឺគេបានឱ្យលុយខ្លួនចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ហើយពេលទៅលោះប្លង់។ ខ្លួនមិនបានដឹងថាឈ្មោះ[redacted] ជឿន មានប្លង់នោះទេ។

ដែលតាមចម្លើយនោះគ្រាន់តែជាការឆ្លើយដោះសារ ដើម្បីឱ្យរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ពុំ



Scanned with CamScanner

មានភស្តុតាងថ្មីសម្រាប់ដោះបន្ទុកឡើយ ដោយហេតុថាតាមចម្លើយរបស់សាក្សី ឈ្មោះ [redacted] ស៊ីផាន់ ជាស្មៀនឃុំអន្លង់ត្នោត បានឆ្លើយថា ៖ឈ្មោះ [redacted]សូម បានយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុមកបញ្ជាក់នៅភូមិ ឃុំដើម្បីទៅយកប្រាក់ខ្ចីធនាគារ រួចអាជ្ញាធរបានចេញឱ្យ។ បន្ទាប់មកឈ្មោ[redacted]ឿន បានឈូសឆាយដី ស្រាប់តែឈ្មោះ [redacted] សូម បានអះអាងថាជាដីគាត់ បន្ទាប់មកអ្នកទាំងពីរបានមកសាលាឃុំ ហើយអ្នកទាំងពីរ បានបង្ហាញប្លង់លើដីដែលទំនាស់នោះរៀងខ្លួន ក្រោយមកទើបអាជ្ញាធរដឹងថាដីខាងលើនេះមាន ប្លង់ចំនួនពីរទៅវិញ ដោយប្លង់របស់ឈ្មោះ[redacted]ជឿន ជាម្ចាស់កម្មសិទ្ធិ។ ខ្លួនមិនដែលឃើញឈ្មោះ [redacted] សូម និងឈ្មោះ [redacted] ជឿន លក់ទិញដីជាមួយគ្នានោះទេ។ ហើយខាងអាជ្ញាធរ បានដោះស្រាយដោយឈ្មោះ[redacted]សូម បានប្រគល់ដីឱ្យទៅឈ្មោះ [redacted] ជឿន វិញដោយឈ្មោះ [redacted] សូម ទាមទាមប្រាក់ចំនួន ៧៥០០ ដុល្លារ ដើម្បីយកលោះប្លង់នៅធនាគារ ហើយឈ្មោះ [redacted] ជឿន បានប្រគល់ប្រាក់ឱ្យហើយបានយកប្លង់មកវិញ និងបានប្រគល់ជូនទៅឈ្មោ[redacted]ជឿន។ ហើយឈ្មោះ ទាំ សូម បានព្រមផ្តិតមេដៃប្រគល់សិទ្ធិកាន់កាប់ឱ្យឈ្មោះ [redacted] ជឿន វិញ។ ដោយចម្លើយសាក្សីនេះ ស៊ីសង្វាក់ជាមួយគ្នានឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជឿន ដែលមានតម្លៃជាភស្តុតាង បញ្ជាក់ថាឈ្មោ[redacted]សូម បានប៉ះពាល់កម្មសិទ្ធិឯកជនប្រាកដមែន។

៥. **យល់ឃើញថា** មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted]សូម ពីបទ ប៉ះពាល់កម្មសិទ្ធិឯកជន ប្រព្រឹត្តនៅភូមិខ្លាក្រពើ ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៩ បទល្មើសមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២៤៨ និងមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ។

៦. **យល់ឃើញថា** តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ចំពោះរឿងនេះជនជាប់ចោទដែលជាអ្នកប្តឹងឧទ្ធរណ៍ គឺមិនបានឆ្លើយនៅចំពោះមុខអង្គសវនាការ ដោយលើកភស្តុតាង ឬហេតុផលដើម្បីបន្ថែមទៅលើសំណុំរឿងទេ ដូច្នេះតំណាងមហាអយ្យការមិនមានអ្វីត្រូវសន្និដ្ឋានបន្ថែម គប្បី ក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមសាលាដំបូង ទុកជាបានការ។

ដែលតាមសេចក្តីសន្និដ្ឋាន និងប្តឹងសុំនេះ មានមូលដ្ឋានអាចឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ បាត់ដំបង លើកយកមកពិចារណា និងសម្រេចតាមការប្តឹងសុំ។

៧. **យល់ឃើញថា** លោក [redacted]ចន្ទុល ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ឆ្លងកាត់តាមការត្រួតពិនិត្យឯកសារ ក៏ដូចជាចម្លើយរបស់កូនក្តីរបស់ខ្លួន ឃើញថាកូនក្តីរបស់ខ្លួនពិតជាម្ចាស់កម្មសិទ្ធិពិតប្រាកដមែន ដែលមានឯកសារប្លង់រឹងតាំងពីឆ្នាំ២០០៧ [illegible] ដែលមានគល់បញ្ជីត្រឹមត្រូវ ហើយជនជាប់ចោទត្រូវជាបងប្អូន និងសុំកូនក្តីរបស់ខ្លួនស្នាក់នៅតែប៉ុណ្ណោះ មូលហេតុដែលមានអង្គហេតុមកជំនុំជម្រះនៅថ្ងៃនេះគឺដោយសារតែឈ្មោះ [redacted]សូម គាត់បានលួចធ្វើប័ណ្ណកម្មសិទ្ធិថ្មីនៅឆ្នាំ២០១៣ ដោយធ្វើការយកប្លង់ទៅដាក់ធនាគារថែមទៀត។ ម្យ៉ាងទៀតកូនក្តីរបស់ខ្លួន និ[redacted]សូម បានធ្វើការសម្របសម្រួលគ្នានៅឆ្នាំ២០១៩ ដោយជនជាប់ចោទបានសុខចិត្តប្រគល់ដីឱ្យកូនក្តីរបស់ខ្លួន ហើយកូនក្តីរបស់ខ្លួនបានឱ្យប្រាក់ចំនួន ៧៥០០$ ដើម្បីយកទៅរំលស់ប្លង់នៅធនាគារទៀត ដែលមានឯកសារជាភស្តុតាងត្រឹមត្រូវ។ ម្យ៉ាងទៀតការអះអាងរបស់គាត់នៅក្នុងសវនាការនៅឆ្នាំ២០២០ ពាក់ព័ន្ធសាលក្រម



Scanned with CamScanner

លេខ ៦៥១-ក- ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ គាត់ថាយកតាំងពីឆ្នាំ២០១៤ ប៉ុន្តែដីជាក់ស្តែងទិញក្នុងឆ្នាំ២០១៦ ដូច្នេះការអះអាងរបស់ជនជាប់ចោទ ធ្វើយ៉ាងមិចក៏ដោយ ដើម្បីយកដីចេញពីកូនក្តីរបស់ខ្លួនដែលជាម្ចាស់កម្មសិទ្ធិស្របច្បាប់។ ស្នើសុំឯកភាពទៅនឹងសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ។

ដែលតាមសេចក្តីសន្និដ្ឋាននេះ មានមូលដ្ឋានគ្រប់គ្រាន់ អាចឱ្យសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបង លើកយកមកពិចារណា។

៨. **យល់ឃើញថា** សាលក្រមព្រហ្មទណ្ឌលេខៈ ២៣(ឝ) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលបានសម្រេចមកនេះមានសំអាងហេតុត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បី សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍បាត់ដំបង សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តពោធិ៍សាត់ ទុកជាបានការ។

**ហេតុដូច្នេះសម្រេច**

១. ទទួលយកពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ[redacted] សូម ទុកជាត្រឹមត្រូវតាមទម្រង់តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២. តម្កល់ សាលក្រមព្រហ្មទណ្ឌលេខៈ ២៣(ឝ) ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តពោធិ៍សាត់ ទុកជាបានការ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]រឿន និងកំបាំងមុខជនជាប់ចោទឈ្មោ[redacted]សូម តែចាត់ទុកជាចំពោះមុខ។

ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

បាត់ដំបង ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner